*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៤*

**សេចក្តីសំរេច លេខ ១១២ សសរ**

**ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង**

**សំរាប់រៀបចំនីតិវិធី និង បែបបទ នៃការនាំចូល និងនាំចេញទំនិញ**

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-ផ្អែកតាមសភាពការណ៍ចាំបាច់

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយ សំរាប់រៀបចំនិតិវិធី និង បែបបទនៃការនាំចូល និងនាំចេញ ទំនិញដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- | ឯកឧត្តម គាត ឈន់ | ប្រធាន |
| ២- | ឯកឧត្តម អ៊ឹង គៀត | សមាជិក |
| ៣- | ឯកឧត្តម ពូ សុធីរះ | សមាជិក |
| ៤- | ឯកឧត្តម ទាំ ហួត | សមាជិក |
| ៥- | ឯកឧត្តម ចម ប្រសិទ្ធិ | សមាជិក |
| ៦- | ឯកឧត្តម ឯក សិរីវុឌ្ឍ | សមាជិក |
| ៧- | ឯកឧត្តម អ៊ឹម ឈុនលឹម | សមាជិក |
| ៨- | ឯកឧត្តម អ៊ិត និជិក | សមាជិក |
| ៩- | ឯកឧត្តម ឈាង យ៉ាំណារ៉ា | សមាជិកប្រចាំការ |

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

១- រៀបចំធ្វើសេចក្តីព្រាងអនុក្រឹត្យមួយស្តីពីនីតិវិធី និង បែបបទនៃការនាំចូល និង នាំចេញទំនិញពីក្នុងព្រះរាជណាចក្រកម្ពុជាដាក់ថ្វាយ និង ជូនគណៈរដ្ឋមន្ត្រី ។

២- ខ្លឹមសារសំខាន់ៗ នៃសេចក្តីព្រាងអនុក្រឹត្យនេះ ត្រូវយកចិត្តទុកដាក់ទៅលើ :

\+ នីតិវិធីនិងបែបបទនៃការនាំចូល និងនាំចេញទំនិញ សំភារៈបរិក្ខា វត្ថុធាតុដើម គ្រឿងបន្លាស់ ។ល។ របស់អតិថិជនក្រុមហ៊ុន និង វិនិយោគិននានា ដើម្បីធានាអោយការងារនេះ ប្រព្រឹត្តទៅដោយសុវត្ថិភាព និង ឆាប់រហ័សទាន់ពេលវេលា ។

\+ ការកំណត់តួនាទីភារកិច្ចអោយបានច្បាស់លាស់បំផុតអោយអង្គភាពគយ និងអង្គភាពមានសមត្ថកិច្ចនានា ដែលធ្វើការនៅកំពង់ផែក្រុងព្រះសីហនុ ក្រុងភ្នំពេញ និងព្រលានយន្តហោះពោធិចិនតុង និងច្រកព្រំដែនដទៃទៀតដែលរដ្ឋបានកំណត់ ។

\+ ការកំណត់ថេរៈវេលា នៃការបំពេញបែបបទ និងការដោះស្រាយលិខិតឯកសារពាក់ព័ន្ធក្នុងការនាំចូល និងនាំចេញទំនិញសំភារៈបរិក្ខា វត្ថុធាតុដើម គ្រឿងបន្លាស់ ។ល។ អោយដល់អង្គភាពគយ និងអង្គភាពមានសមត្ថកិច្ចនានា ដែលប្រចាំការនៅកំពង់ផែព្រលានយន្តហោះ និងច្រកព្រំដែននានា ។ ក្នុងករណីយឺតយ៉ាវដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវមានវិធានការ និងដាក់ពិន័យចំពោះជនល្មើសតាមច្បាប់កំណត់ ។

៣-លើកវិធានការអោយបានហ្មឹងម៉ាត់ ដើម្បីលុបបំបាត់ប៉ុស្តិ៍ត្រួតពិនិត្យមិនស្របច្បាប់នៅតាមដងផ្លូវជាតិនានា សំដៅធានាសន្តិសុខសណ្តាប់ធ្នាប់ និងលុបបំបាត់ការជុំរិតយកប្រាក់ពីមធ្យោបាយដឹកជញ្ជូនពីសេសផ្លូវជាតិលេខ៤ ដែលជា ផ្លូវសំខាន់បំផុតនៃខឿនសេដ្ឋកិច្ចជាតិ ។

៤-លើករវិធានការបង្កើនកិច្ចការពារផ្លូវដែក ភ្នំពេញ-ក្រុងព្រះសីហនុ ដើម្បីត្រៀមបង្វែរការដឹកជញ្ជូនតាមផ្លូវដែកជំនួសផ្លូវជាតិលេខ៤ ដែលនឹងត្រូវជួសជុលនៅពេលខាងមុខនេះ ។

៥-ពិចារណារៀបចំគំរោងកសាងផែគោក និង រៀបចំបង្កើតភ្នាក់ងាររត់ការយកកុំរ៉ៃនៅតំបន់កំពង់ផែ ព្រលានយន្តហោះ និងច្រកព្រំដែននានាដែលរដ្ឋបានកំណត់ ។

ប្រការ ៣ : សមាជិកគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

-គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីសំរួលការងារ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ឯកឧត្តមដែលមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១
ព្រះហស្ថលេខា និង ត្រា
**នរោត្តម រណឫទ្ធិ**

* * *